ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# លោកវេជ្ជបណ្ឌិត ភីធើ វ៉ាន់ ម៉ារ៉ែន Pieter Van Maaren តំណាង

# អង្គការសុខភាពពិភពលោក

# ជួបសំដែងការគួរសមជូនដល់ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី និង

# ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# នៅថ្ងៃទី១០ ខែមករា ឆ្នាំ ២០០១៤

កាលពីថ្ងៃទី ១០ មករា ២០១៤ នៅទីស្នាក់ការកណ្តាលអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ **ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី** និង ជាប្រធានអាជ្ញាធរជាតិនេះ បានទទួលស្វាគមន៍យ៉ាងកក់ក្តៅចំពោះ លោកវេជ្ជបណ្ឌិត ភីធើ វ៉ាន់ ម៉ារ៉ែន Pieter Van Maaren តំណាង អង្គការសុខភាពពិភពលោក សម្រាប់ការសំដែងការគួរសមនេះបន្ទាប់ពី ឯកឧត្តមប្រធាន ចូលកាន់តំណែងជាផ្លូវការកាលពី ខែតុលា ឆ្នាំ ២០១៣ កន្លងទៅ ។ ឯកឧត្តមប្រធាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានគូសបញ្ជាក់នូវការដាក់ចេញនូវគោលនយោបាយ ៧ ចំណុច របស់រាជរដ្ឋាភិបាលកម្ពុជា តាមសេចក្តីជូនដំណឹង (ស.ជ.ណ) របស់ទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ១៧ ខែធ្នូ ២០១៣ តាមការចង្អុលបង្ហាញ ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន** ។ ចំណុចមួយក្នុងចំណោម ចំណុច ទាំងនោះ បានបញ្ជាក់ថា អាជ្ញាធរ ជាតិប្រយុទ្ធនឹងជំងឺអេដស៍មានតួនាទីនាំមុខលើប្រសិទ្ធិភាពជំនួយ និង ទទួលខុសត្រូវសម្រាប់ការឆ្លើយតបមេរោគអេដស៍ និង ជំងឺអេដស៍ នៅទូទាំងប្រទេស ។ ឯកឧត្តម ប្រធាន អ.ជ.ប.ជ.អ. បានរំលឹកតំណាងអង្គការសុខភាពពិភពលោកថា **សម្តេច នាយករដ្ឋមន្ត្រី** បានធ្វើការកែសំរួលរចនាសម្ព័ន្ធនៃ អ.ជ.ប.ជ.អ. សម្រាប់ធ្វើឱ្យប្រសើរឡើងនូវកិច្ចសហការ រវាង ភាគីពាក់ព័ន្ធ ដ៏សំខាន់ៗនានាដែលបំរើការឆ្លើយតបនឹងមេរោគអេដស៍ និង ជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជា ។ ការកែសំរួល នេះក៏មានការតែងតាំង **ឯកឧត្តម ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវបានតែងតាំង ជាអនុប្រធាន ទី ១ នៃ អ.ជ.ប.ជ.អ.ផងដែរ។ទាក់ទងនឹងការរៀបចំសមាជិកភាព និងជាប្រធាននៃគណៈកម្មាធិការសំរបសំរួល

មូលនិធិសកលកម្ពុជាសំរាប់ដំណើរការរបស់ខ្លួននៅក្នុង អណ្តត្តិ២០១៤-២០១៥ នេះ លោកវេជ្ជបណ្ឌិត ភី ធើ វ៉ាន់ ម៉ាវ៉ែន Pieter Van Maaren ជំរាបជូន ឯកឧត្តម ប្រធាន អ.ជ.ប.ជ.អ. អំពី តួនាទី ឈានមុខ របស់រដ្ឋាភិបាល ក្នុងយន្តការ ដ៏សំខាន់នេះពិសេសលើការ ត្រួតពិនិត្យ (Oversight ) ការអនុវត្តគំរោង ជំនួយ សម្រាប់ ការឆ្លងមេរោគអេដស៍ និង ការឆ្លើយតប ជម្ងឺអេដស៍ ក៏ដូចជាជំងឺគ្រុនចាញ់ និង របេង ព្រមទាំងការពង្រឹងប្រព័ន្ធសុខាភិបាលនៅក្នុងប្រទេសកម្ពុជាផងដែរ ។ ក្នុងន័យនេះ តំណាងមកពីក្រុម ប្រឹក្សាអភិវឌ្ឍន៍ជាតិ និងស្ថាននិតិសម្បទា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល អាជ្ញា ធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង ក្រសួងផ្សេងទៀតអាច ស្នើដាក់បេក្ខភាពរបស់ខ្លួនសម្រាប់ការបោះ ឆ្នោតជ្រើសរើសជាប្រធាន នៃគណៈកម្មាធិការសំរបសំរួលមូលនិធិសកលកម្ពុជា ដែលគ្រោងនឹងធ្វើ ឡើងនៅថ្ងៃ ទី ១៦ខែមករា ឆ្នាំ ២០១៤ ខាងមុខនេះ ។ ឯកឧត្តមប្រធាន អ.ជ.ប.ជ.អ លើកពីមេរៀនពី កិច្ចប្រជុំអន្តរជាតិនៃតំបន់អាស៊ី និង ប៉ាស៊ីហ្វិកលើកទី១១ (ICAAP 11) ហើយបានសង្កត់ធ្ងន់ ថាប្រទេស កម្ពុជានឹងចាប់យកនូវគំនិតថ្មីៗ (Innovations) មកអនុវត្តក្នុងភាពជាអ្នកដឹកនាំ និង ការគ្រប់គ្រង នៃការ ឆ្លើយតប មេរោគអេដស៍ និង ជំងឺអេដស៍ ។ "Not Business as Usual ( ការដឹកនាំការឆ្លើយតបនឹងជំងឺអេដ ស៍មិនអាចបន្តធម្មតាៗដូចមុនបានទេ) " នឹងជា បាវចនា សម្រាប់ពង្រឹងគណនេយ្យភាពទ្វេទិសដើម្បី ទទួល ខុសត្រូវចំពោះ លទ្ធផល នៃការឆ្លើយតបព្រមទាំងប្រសិទ្ធិភាព និង ប្រសិទ្ធផលនៃការឆ្លើយតប ទាំង នោះផងដែរ ។ យើងមានការប្តេជ្ញាខិតខំប្រឹងប្រែង ដើម្បីជៀសវាង បទពិសោធន៍ ដែលកន្លងទៅ ការប្រើប្រាស់ ថវិកា ពុំទាន់បានសមស្របនឹងសេចក្តីត្រូវការតាមតំបន់និងតាមកម្មវិធី ។ សម្រាប់ និរន្តភាព យើងត្រូវ ស្វែងរកជម្រើស មួយដើម្បី នាំទៅដល់ដំណោះស្រាយ រយៈពេលវែង ដែលមានជា អាទិ៖ ការដាក់បញ្ចូលការងារអេដស៍ នៅក្នុងប្រព័ន្ធសុខាភិបាល និង វិស័យគន្លឹះមួយចំនួនទៀត។ ការ ជួយផ្តល់ជីវភាពដល់ អ្នកផ្ទុកមេរោគអេដស៍ និង កុមារកំព្រាដោយមេរោគអេដស៍តាមរយៈកម្មវិធី គាំពារសង្គម ត្រូវបាន គេមើលឃើញថា មិនត្រឹមតែជាកាតព្វកិច្ច ដែលមានមូលដ្ឋានសិទ្ធិមនុស្ស ប៉ុណ្ណោះទេ ប៉ុន្តែ ជាចំណែកមួយដ៏ល្អមួយសម្រាប់ធានាឲ្យអ្នកប្រើថ្នាំប្រឆាំងមេរោគអេដស៍មកយកថ្នាំ នៅក្នុងប្រព័ន្ធសុខាភិបាលយ៉ាងទៀងទាត់។

សម្រាប់ការ ពង្រឹងយន្តការជាតិឆ្លើយតបនឹងមេរោគអេដស៍ និង ជំងឺអេដស៍នៅក្នុងប្រទេស ឯកឧត្តម ប្រធាន សង្កត់ធ្ងន់ថា អ.ជ.ប.ជ.អ. បើកចំហជាមួយអ្នកពាក់ព័ន្ធដើម្បីពង្រឹងកិច្ចសហការ ពិសេសលើ ជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព បច្ចេកទេស និង ស្ថាប័ន នៃ ក្រុមមន្ត្រី រដ្ឋាភិបាល ។ លើបញ្ហា នេះ លោកវេជ្ជបណ្ឌិត ភីធើ វ៉ាន់ ម៉ាវ៉ែន Pieter Van Maaren បាន បន្ថែមទៀត ថាក្រោមគោលការណ៍ "ឲ្យ និង យក( giving and taking process)" ទីប្រឹក្សាបច្ចេកទេសក៏ ត្រូវរៀនសូត្រពីប្រព័ន្ធ ប្រទេសផងដែរ ដើម្បីអនុវត្តភារកិច្ចទៅ ប្រកបដោយប្រសិទ្ធភាព ។